**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ: ១៧៨/...... សសរ

# សេចក្ដីសម្រេច
# ស្ដីពី
## ការកែសម្រួលសមាសភាពក្រុមការងារអនុវត្តច្បាប់

### គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្ដីសម្រេចលេខ ១៩០ សសរ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- យោងសំណើលេខ១៥៥/២៥សណ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៥ របស់ប្រធានក្រុមការងារអនុវត្តច្បាប់

# សម្រេច

**ប្រការ១.**

ត្រូវបានកែសម្រួលសមាសភាពក្រុមការងារអនុវត្តច្បាប់របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានរាយនាមដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមនាយឧត្តមសេនីយ៍ | **ស ថេត** | អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | ប្រធាន |
| ២-ឯកឧត្តមឧត្តមសេនីយ៍ឯក | **ជិន ផល្លី** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ | អនុប្រធានអចិន្ត្រៃយ៍ |

| | | | |
|---|---|---|---|
| ៣-លោកជំទាវឱសថការី | **លី គីមអេង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៤-ឯកឧត្តម | **តាន់ សេណារ៉ុង** | ព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ | អនុប្រធាន |
| ៥-លោកឧត្តមសេនីយ៍ទោ | **តែ សុថារេត** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | អនុប្រធាន |
| ៦-លោកឧត្តមសេនីយ៍ទោ | **សុក សំបូរ** | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃអគ្គស្នង-ការដ្ឋាននគរបាលជាតិ | អនុប្រធាន |
| ៧-លោកជំទាវ | **ម៉ែន ផល្លីការ** | ប្រធាននាយកដ្ឋានកិច្ចការយុត្តិធម៌ព្រហ្មទណ្ឌ និងនគរបាលយុត្តិធម៌ នៃក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៨-លោក | **យូ សុតាំក្រ** | ប្រធាននាយកដ្ឋានគាំពារជនរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | អនុប្រធាន |
| ៩-លោកជំទាវឧត្តមសេនីយ៍ឯក | **លឹម រស្មី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ | សមាជិកា |
| ១០-ឯកឧត្តមឧត្តមសេនីយ៍ឯក | **អ៊ុក ហៃសីឡា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ១១-លោក | **ជួប ណារ៉ាត់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១២-លោក | **ស៊ុំ វណ្ណារ័ត្ន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី | សមាជិក |
| ១៣-លោក | **សេង សុជាតិ** | ប្រធាននាយកដ្ឋានកិច្ចការកុងស៊ុលនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤-លោកឧត្តមសេនីយ៍ទោ | **វ៉ែន មុន្នីរ័ត្ន** | នាយករងទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន នៃក្រសួងការពារជាតិ | សមាជិក |
| ១៥-លោកឧត្តមសេនីយ៍ទោ | **សុខ ទី** | អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នង-ការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៦-លោកស្រី | **កេត សារ័ត្ន** | អនុប្រធាននាយកដ្ឋានការពារផ្លូវច្បាប់ នៃក្រសួងកិច្ចការនារី | សមាជិកា |
| ១៧-លោកស្រីវរសេនីយ៍ទោ | **ហ្វាង ឈីងឈីង** | ស្នងការរង នៃស្នងការដ្ឋានស្រាវជ្រាវនិងបង្ក្រាបបទល្មើស នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិកា |
| ១៨-លោកវរសេនីយ៍ឯក | **ស៊ុំ ផាន់ណា** | នាយការិយាល័យរដ្ឋបាល-សរុប នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |

១៩-លោកវរសេនីយ៍ទោ **ហ៊ាង វាសនា** នាយរងការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃស្នងការដ្ឋានស្រាវជ្រាវ និងបង្ក្រាបបទល្មើស នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

២០-តំណាងអង្គការដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិ សមាជិក

**ប្រការ២._**

ប្រធាន អនុប្រធានអចិន្ត្រៃយ៍ អនុប្រធាន សមាជិក និងសមាជិកា ក្រុមការងារអនុវត្តច្បាប់ ត្រូវអនុវត្តតាមតួនាទី និងភារកិច្ចដូចមាន ចែងក្នុងប្រការ៥ នៃសេចក្ដីសម្រេចគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លេខ ០៩៤/១៤ សសរ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួងស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឱ្យមានប្រសិទ្ធភាព។

ប្រធានក្រុមការងារអាចចាត់តាំងមន្ត្រី ជាជំនួយការតាមការចាំបាច់។

អង្គការដៃគូពាក់ព័ន្ធជាតិ អន្តរជាតិ ដែលមានគោលដៅស្របទៅនឹងភារកិច្ចដែលកំណត់ដោយសេចក្ដីសម្រេចលេខ ០៩៤/១៤ សសរ ខាងលើ អាចស្នើសុំចូលជាសមាជិកក្រុមការងារមកប្រធានក្រុមការងារអនុវត្តច្បាប់ និងចាត់តំណាងផ្លូវការមកចូលរួម តាមការអញ្ជើញរបស់ប្រធានក្រុម។

**ប្រការ៣._**

សេចក្ដីសម្រេចលេខ០៦៣ សសរ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងសមាសភាពក្រុមការងារអនុវត្តច្បាប់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារ នៃសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤._**

អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អង្គការដៃគូពាក់ព័ន្ធជាតិ អន្តរជាតិ និងសាមីខ្លួនដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ៧.១៩កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**អភិសន្តិបណ្ឌិត ស សុខា**

កន្លែងទទួល៖

- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*
- *សមាជិក សមាជិកា គ.ជ.ប.ជ*
- *ដូចប្រការ៤*
- *ឯកសារ កាលប្បវត្តិ*